ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

## កំណត់ហេតុប្រជុំ ផ្តល់យោបល់លើការពិនិត្យឯកសារពិគ្រោះ "ប្រវត្តិកម្ពុជាប្រជាធិបតេយ្យ"

កាលពីថ្ងៃទី ដប់បួន ខែធ្នូ ឆ្នាំពីរពាន់ប្រាំមួយ វេលាម៉ោង បី និង ដប់ប្រាំនាទី ល្ងាច នៅសាលប្រជុំរបស់ក្រសួងអប់រំ យុវជន និងកីឡា មានបើកិច្ចប្រជុំពិគ្រោះយោបល់លើឯកសារ "ប្រវត្តិកម្ពុជាប្រជាធិតេយ្យ" តាមសេចក្តីសំរេចលេខ ៧៧ សសរ. ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ។

សមាសភាចូលរួមប្រជុំ (បញ្ជីជូនភ្ជាប់):

១. ឯកឧត្តម **ស៊ិន សំណាង**

២. ឯកឧត្តម **រស់ ចន្ទ្រាបុត្រ**

៣. ឯកឧត្តម **ឆយ អូន**

៤. ឯកឧត្តម **អៀត សុខ**

៥. លោកស្រី **ឆន់ សារ៉ឹម**

៦. លោក **គួយ ធាវី**

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **អ៊ឹម សិទ្ធី** បានសំដែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តមអស់លោក លោកស្រី ក្នុងការចូលរួមប្រជុំពិគ្រោះយោបល់ទៅលើឯកាសារ "ប្រវត្តិកម្ពុជាប្រជាធិតេយ្យ" និងគូសបញ្ជាក់ថា: ខ្ញុំសូមរំលឹកពីការខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការកសាងកម្មវិធីសិក្សា និងនិពន្ធសៀវភៅសិក្សាថ្មី ជាពិសេសមុខវិជ្ជាប្រវត្តិវិទ្យា ដែលសិស្សត្រូវសិក្សានៅសាលារៀនចំណោះទូទៅ ។ ការខិតខំប្រឹងប្រែងកន្លងមកនេះ បានទទួលរងនូវការទិតៀនយ៉ាងច្រើន ជាពិសេសចំពោះរឿងដែលសរសេរពាក់ព័ន្ធជាមួយខ្មែរក្រហម ការបង្ហាញតថភាពតាមរយៈរូបភាពបែបហិង្សា ការប៉ះពាល់ដល់ផលប្រយោជន៍បុគ្គលជាដើម ។ល។ បញ្ហាសរសេរប្រវត្តិសាស្ត្រដែលទាក់ទងនឹងរបបមុនៗ មានការលំបាកច្រើន ដែលបណ្តាលមកពីអាយុកាលនៃបំរែបំរួលនៅក្នុងរបបនយោបាយមានរយៈពេលខ្លី ហើយការពិតទាំងនោះប្រហែលជាមិនទាន់បានក្លាយទៅជាប្រវត្តិសាស្ត្រ សំរាប់លើកមកសិក្សា។

បើពិនិត្យទៅលើសេចក្ដីសម្រេចលេខ **៧៧** សសរ. របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីការបង្កើតក្រុមការងារ ឃើញថា មានការចង្អុលបង្ហាញច្បាស់អំពីភារកិច្ចនៃក្រុមការងារ ។ ខ្ញុំក៏បានពិនិត្យលិខិតរបស់លោក ឆាង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ញើជូនឯកឧត្តម កុល ផេង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៦ ។ ខ្ញុំសូមលើកជាឧទាហរណ៍មួយចំនួន ដែលជាបទពិសោធទាក់ទងទៅនឹងបញ្ហាប្រវត្តិសាស្ត្រស្មុគ្រស្មាញនៃប្រទេសនៅក្នុងតំបន់ ដូចជាជប៉ុន កូរ៉េ និងចិន និងការប្រឈមមុខរបស់យើង ដើម្បីដោះស្រាយបញ្ហាឱ្យសិស្សមានសៀវភៅសិក្សា ទន្ទឹមនឹងពេលដែលយើងមិនទាន់បានបង្កើតរាជបណ្ឌិតសភា និងមិនទាន់មាន ច្បាប់អប់រំ ។ សូមអង្គប្រជុំចូលរួមផ្ដល់ជាយោបល់ ។

ឯកឧត្តម **ស៊ន សំណាង** -រាជបណ្ឌិតសភាធ្លាប់ទំនាក់ទំនង និងបានធ្វើការកន្លងមកជាមួយមជ្ឈមណ្ឌមឯកសារកម្ពុជា ។ តែបើមានសំណើពីក្រសួងអប់រំ យុវជន និងកីឡាឱ្យជួយពិនិត្យ និងកែលំអ ទោះបីមានប្រាក់ឧបត្ថម្ភ ឬគ្មាន ក៏ខាងរាជបណ្ឌិតសភាចូលរួមជួយកែលំអដែរ ។ ផ្ទុយទៅវិញបើគ្មានសំណើទេ ខាងរាជបណ្ឌិតសភាមិនចូលរួមជួយកែលំអឡើយ ។ ដោយឡែកចំពោះឯកសារ "ប្រវត្តិកម្ពុជាប្រជាធិតេយ្យ" វិញ ខ្ញុំពិនិត្យឃើញថា មានការបរិយាយហួសដែនកំណត់រវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដោយរៀបរាប់ពីរបបនយោបាយនីមួយៗ អ្នកនិពន្ធគួរកត់សំគាល់លើពាចំណុចធំៗ គឺបុព្វហេតុ ដំណើរប្រព្រឹត្តទៅ និងផលវិបាក ។ បុព្វហេតុត្រូវមានបុព្វហេតយូរអង្វែង និងបុព្វហេតុផ្ទាល់ ។ ចំពោះឯកសារ "ប្រវត្តិកម្ពុជាប្រជាធិតេយ្យ" បាននិយាយលើចំណុចបុព្វហេតុនេះវែងអន្លាយពេក ដោយបានបង្ហាញឈ្មោះមនុស្សយ៉ាងច្រើន ។ ជាយោបល់ គឺគួរតែនិយាយសង្ខេបអំពីបុព្វហេតុ ហើយបន្ថយការបង្ហាញឈ្មោះមនុស្ស ដោយខិតខំបង្ហាញពីព្រឹត្តិការណ៍តាមលក្ខណៈសត្យានុម័ត ហើយគួរចៀសវាងការធ្វើវិនិច្ឆ័យ តាមគំនិតផ្ទាល់ខ្លួន ។ លើសពីនេះទៀត អ្នកនិពន្ធត្រូវតែខំពន្យល់ពីរបបគ្រប់គ្រងឱ្យបានច្រើន ។

ពាក់ព័ន្ធទៅនឹងសំណើរបស់មជ្ឈមណ្ឌលឯកសារ ដែលស្នើសុំយោបល់ក្នុងការប្រើប្រាស់ឯកាសារ "ប្រវត្តិកម្ពុជាប្រជាធិតេយ្យ" ដោយផ្នែក ឬទាំងស្រុងនៅក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យ ឬប្រើប្រាស់ជាឯកសារជំនួយស្មារតិសម្រាប់សិស្សានុសិស្សទូទៅ ជាយោបល់ប្រសិនបើក្រសួងអប់រំ យុវជន និងកីឡា យល់ព្រមអនុញ្ញាតឱ្យប្រើប្រាស់ឯកសារនេះក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យ ក្រសួងគួរតែថ្លឹងថ្លែងពីសមាមាត្រដ៏សមស្របមួយ រវាងម៉ោងសិក្សា ចំនួនទំព័រ ចំនួនផ្នែក ចំនួនជំពូក និងចំនួនមេរៀនសម្រាប់សិក្សាលើមុខវិជ្ជាប្រវត្តិវិទ្យានេះ ដោយធៀបនឹងមេរៀន និងមុខវិជ្ជាដទៃទៀត។ សូមស្នើឱ្យបន្ថយក្នុងការរៀបរាប់ឈ្មោះបុគ្គល ដែលជាប្រយោជន៍ដើម្បីការពារសន្តិសុខនៃបុគ្គលនោះ ហើយគួរកំណត់ថាជាប្រវត្តិសាស្ត្រថ្មី ដោយគិតត្រឹមប្រទេសកម្ពុជាទទួលបានឯករាជ្យ ។ ប្រវត្តិសាស្ត្រក្រោយសម័យឯករាជ្យ មានឥទ្ធិពល និងផលប៉ះពាល់ច្រើនដល់អ្នកនៅរស់ ដូច្នេះគេគួរទុកវាយ៉ាងតិចរយៈពេល៦០ឆ្នាំទើបលើកយកមកនិយាយ ហើយបើលើកយកមកនិយាយ គេគួរតែខំនិយាយដោយផ្ដោតលើតែចំណុចសំខាន់ៗ ដូចជាព្រឹត្តិការណ៍ និងរបបនយោបាយ ចំណែកមនុស្ស គេគួរតែបង្ហាញមនុស្សសំខាន់ៗ ដែលពាក់ព័ន្ធផ្ទាល់ក្នុងការគ្រប់គ្រងរបបនយោបាយ ជាការគ្រប់គ្រាន់ ។

ជាមួយនេះ គេក៏គួរតែវិភាគផងដែរ អំពីផលវិបាករបស់វាទៅលើវិស័យផ្សេងៗ ចរន្តលើសកលលោកដើម្បីគាំទ្រសន្តិភាព ការប្រកាសរបស់អង្គការសហប្រជាជាតិយកឆ្នាំ ២០០០ ជាឆ្នាំសន្តិភាព ការបញ្ចប់សង្គ្រាមត្រជាក់ ការជ្រៀតជ្រែកនៃសង្គ្រាមវប្បធម៌ ដំណើរការផ្សះផ្សាជាតិរបស់កម្ពុជា និងការលើកសរសើរបុព្វបុរស ។ ចំពោះឯកសារ "ប្រវត្តិកម្ពុជាប្រជាធិតេយ្យ" បើសិនមានការស្នើកែប្រែដោយគណៈកម្មការ មជ្ឈមណ្ឌលត្រូវតែធ្វើការកែប្រែតាម បើមិនដូច្នោះទេ មិនអនុញ្ញាតឱ្យប្រើប្រាស់ក្នុងកម្មវិធីសិក្សាចំណេះទូទៅ ប៉ុន្តែមជ្ឈមណ្ឌលឯកសារអាចបោះពុម្ពឯកសារនេះបានសម្រាប់ប្រើប្រាស់ទូទៅ ។ ដោយឡែក នៅថ្នាក់ឧត្តមសិក្សាវិញ អ្នកសិក្សាមានសេរីភាពគ្រប់គ្រាន់ក្នុងការសរសេរ ការអាន និងការវិភាគ ។

ឯកឧត្តម **រស់ ចន្ត្រាបុត្រ** - គាំទ្រគំនិតដែលបានលើកឡើងកន្លងមក ។ ដោយឡែកចំពោះឯកសារ "ប្រវត្តិកម្ពុជាប្រជាធិតេយ្យ" ខ្ញុំពិនិត្យឃើញថា នេះជាការគិត ឬ រឿងរបស់ក្រុមមួយ ឬ បុគ្គលម្នាក់ ដូច្នេះមិនអាចយកមកធ្វើជាទូទៅបានឡើយ ។ ម្យ៉ាងទៀតឯកសារនេះ មានការខ្វះខាតច្រើន តែទោះជាយ៉ាងណាក៏ដោយក៏យើងគួរតែកោតសរសើរចំពោះការខិតខំស្រាវជ្រាវ និងចងក្រងឯកសារ នេះឡើង ។ ឯកសារនេះសរសេរច្រើនពេក ពិបាកក្នុងការឱ្យសិស្សនៅសាលារៀនចំណេះទូទៅសិក្សា ចំណែកនៅឧត្តមសិក្សាវិញ ឯកសារនេះមានការខ្វះខាតច្រើន សម្រាប់អ្នកសិក្សានៅថ្នាក់ឧត្តមសិក្សា។ ខ្ញុំសូមស្នើឱ្យក្រសួង អប់រំ យុវជន និងកីឡា គួរពិនិត្យ និងកែលំអឯកសារចាស់ៗដែលបានរៀបចំកន្លងមក យកមកប្រើប្រាស់ឡើងវិញ ។

ឯកឧត្តម **ឆយ អូន** - នេះជាការរៀបចំរបស់មនុស្សម្នាក់ ឬក្រុមមួយ ។ បើពិនិត្យតាមសំណើរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានស្នើដាក់ឯកសារនេះជាឯកសារពិគ្រោះ សំរាប់សាលារៀនចំណេះទូទៅ ។ ដូច្នេះយើងគួរពិនិត្យមើលថា អ្វីទៅជាឯកសារពិគ្រោះ? ហើយតើគេត្រូវធ្វើដូចម្ដេចចំពោះឯកសារពិគ្រោះនេះ? តើយើងគួរយកឯកសានេះទៅអនុវត្ត ឬមិនយកទៅអនុវត្ត ព្រោះវាមិនមែនជាសៀវភៅសិក្សាទេ ។ ឯកសារពិគ្រោះ ជាឯកសារធម្មតាមួយ ដែលអ្នកសិក្សាអាចយកមកពិគ្រោះ ឬ មិនពិគ្រោះក៏បាន ព្រោះនេះជាសេរីភាពរបស់គេ ។

លោក **គួយ ឆាវី** - សៀវភៅនេះមានបីផ្នែកគឺ ការឡើកាន់អំណាច របៀបគ្រប់គ្រងអំណាច និងការដួលរលំនៃអំណាច ។ នៅផ្នែកអារម្ភកថា បានសរសេរថា សៀវភៅនេះត្រូវបានរៀបចំឡើង ដើម្បីទប់ស្កាត់របបប្រល័យពូជសាសន៍កុំឱ្យវិលត្រឡប់មកវិញ ហើយនៅផ្នែកមួយចំនួនបានសរសេររៀបរាប់ធ្វើឱ្យអ្នកអានភ័យតក់ស្លុត ដែលអាចផ្ដល់ផលល្អផង និងផលមិនល្អផង ។ មានមួយផ្នែកទៀតបានសរសេរវិនិច្ឆ័យឱ្យបុគ្គលប៉ុល ពត ថាជាអ្នកជាតិនិយម ហើយបានបង្កប់ន័យទស្សនវិជ្ជាយ៉ាងច្រើន ។ ដូច្នេះយើងបារម្ភថា បើបង្ហាញពីអំពើឃោរឃៅ វានាំឱ្យរឹតតែឃោរឃៅថែមទៀត ។ ឯផ្នែកខ្លះទៀត បានបង្ហាញពីការឡើងកាន់អំណាច របស់បក្សប៉ុល ពត ។ ការបង្ហាញបែបត្រង់នេះមើលទៅហាក់ដូចជា ជំលោះរវៀងក្រុមមួយនឹងក្រុមមួយទៀត ក្នុងការធ្វើអាជីវកម្មនយោបាយ ដើម្បីវាយប្រហារសងសឹកគ្នាទៅវិញទៅមក ។

ឯកឧត្តម **អៀត សុខ** - ឯកភាពចំពោះមតិលើកឡើងខាងលើ ប៉ុន្តែយើងមានការបារម្ភ ក្នុងការយកឈ្មោះគណៈកម្មការទៅប្រើប្រាស់ ដោយមិនបានធ្វើការកែតម្រូវតាមការពិនិត្យរបស់គណៈកម្មការស្នើឡើង ។ ឯកសារពិគ្រោះ ឬមិនពិគ្រោះ វាអាស្រ័យទៅលើអ្នកដែលប្រើប្រាស់ឯកសារនេះសំរាប់ពិគ្រោះ ។ ចំពោះរបៀបសរសេរ ត្រូវសរសេរឱ្យសមស្របក្បួនខ្នាតគរុកោសល្យនៃការសិក្សារបស់សិស្ស ហើយត្រូវមានការសហការជាមួយអ្នកជំនាញរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

លោកស្រី **ឆន់ សារ៉ុម** - បើតាមការស្នើសុំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មកក្រសួង អប់រំ យុវជន និងកីឡា គឺគ្រាន់តែសុំឱ្យយកផ្នែកខ្លះ ឬទាំងស្រុងសម្រាប់ប្រើប្រាស់ជាឯកសារជំនួយស្មារតី ។ ដូច្នេះ យើងអាចយកឯកសារនេះសម្រាប់ជាឯកសារពិគ្រោះក្នុងការតែងនិពន្ធសៀវភៅសិក្សាសម្រាប់សាលារៀនចំណេះទូទៅ ។ មានមូលហេតុច្រើន ចាំបាច់ត្រូវពិចារណាបន្ត ដូចជាតួលេខខុសគ្នាសំរាប់បញ្ហាតែមួយ ខ្វះការឯកភាព និងអាចបង្កឱ្យមានការលំបាកដល់សិស្ស និងអ្នកសិក្សាពីភាពច្បាស់លាស់របស់វា ។ ចំណែកឯនៅក្នុងកម្មវិធីសិក្សា ដែលបានអនុវត្តកន្លងមកនេះវិញ យើងបានឱ្យសិស្សសិក្សា ទាក់ទងនិងរបបកម្ពុជាប្រជាធិបតេយ្យនៅ ថ្នាក់ទី ៩ម្តង និង ថ្នាក់ទី ១២ ម្តងទៀត ដោយថ្នាក់ទី ៩ សិស្សសិក្សានូវចំណុចគោលៗ ហើយសិក្សាលំអិតនៅថ្នាក់ ទី ១២ ។ ចំពោះរឿងសោកនាដកម្ម យើងអាចយកមកពណ៌នាជារឿងនិទាន សំរាប់សិស្សសាលារៀនចំណេះទូទៅ ។ ដូច្នេះ ឯកសារនេះ យើងអាចដកស្រង់យកផ្នែកខ្លះមកពិគ្រោះក្នុងការតែងនិពន្ធសៀវភៅសិក្សា ហើយផ្នែកខ្លះទៀតដាក់ជាមេរៀនប្រវត្តិសាស្ត្រ តែមិនអាចទុកជាសៀវភៅសិក្សាសំរាប់សាលាចំណេះទូទៅឡើយ ។

ឯកឧត្តម **អ៊ឹម សិទ្ធិ** - សៀវភៅនេះបានស្រាវជ្រាវ និងសរសេរបានល្អ សំរាប់អ្នកប្រវត្តិសាស្ត្រ ដើម្បីសិក្សាបន្ត ។ ការសរសេរសៀវភៅប្រវត្តិសាស្ត្រសំរាប់ដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាសាលារៀនចំណេះទូទៅ មានបញ្ហាលំបាកស្មុគ្រស្មាញច្រើន សូម្បីនៅប្រទេសជប៉ុន ដែលជាប្រទេសមានបទពិសោធច្រើនក្នុងការតាក់តែងសៀវភៅសិក្សាប្រវត្តិសាស្ត្រ ក៏នៅតែជួបបញ្ហា ដែលប្រវត្តិសាស្ត្រនោះពាក់ព័ន្ធជាមួយប្រទេសកូរ៉េ និងប្រទេសចិនផងដែរ ។ ថ្មីៗនេះ នាយករដ្ឋមន្ត្រីថ្មីរបស់ប្រទេសជប៉ុន បានបង្ហាញពីបំណង ដើម្បីសរសេរសៀវភៅសិក្សាប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនឡើងវិញ ។ ឯកសារ "ប្រវត្តិកម្ពុជាប្រជាធិតេយ្យ" អាចយកមកប្រើប្រាស់ជា ឯកសារពិគ្រោះសម្រាប់ការតាក់តែង និពន្ធសៀវភៅសិក្សាប្រវត្តិវិទ្យានៅសាលារៀនចំណេះទូទៅតែប៉ុណ្ណោះ ។

ឯកឧត្តម **ស៊ន សំណាង** - សូមឯកភាពយោបល់ឯកឧត្តមប្រធាន ។

ឯកឧត្តម **ឆយ រ៉ុន** - យើងមានការព្រួយបារម្ភ បើគេយកឈ្មោះគណៈកម្មការមកប្រើក្នុងការបោះពុម្ពឯកសារនេះ ។ ដូច្នេះយើងគួររកដំណោះស្រាយសមស្របមួយ ដែលយើងអាចទទួលយកបានទាំងអស់គ្នា គឺសម្រេចយកឯកសារនេះដាក់ជាឯកសារពិគ្រោះ សំរាប់ការនិពន្ធសៀវភៅសិក្សា ព្រោះឯកសារនេះនៅមានភាពខ្វះចន្លោះច្រើនទៀត ដូចជាភាពមិនច្បាស់លាស់ ឬមិនផ្លូវការ ដែលទាក់ទងទៅនឹងប្រវត្តិរបស់បក្សជាដើម ។ ស្នើលុបចោលជំពូកទី២ និងស្នើឱ្យនិយាយតែក្នុងកំលុងរវាងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ។

ឯកឧត្តម **អ៊ឹម សិទ្ធី** - មិនគួរធ្វើការកែតម្រូវឯកសារនេះទេ ព្រោះនេះជាការស្រាវជ្រាវ ការគិត ការវិភាគ ទៅតាមការយល់ឃើញរបស់គេ ដែលជាអ្នកសិក្សាស្រាវជ្រាវ ។ ដូច្នេះយើងគ្រាន់តែស្នើយកជាមូលដ្ឋានសំរាប់ពិគ្រោះនៅក្នុងការតែងនិពន្ធសៀវភៅសិក្សាប្រវត្តិវិទ្យាសំរាប់សាលារៀនចំណេះទូទៅ ដោយត្រូវដកស្រង់យកចំណុចខ្លះៗដាក់បញ្ចូលទៅក្នុងមេរៀនប្រវត្តិវិទ្យា ឬតាក់តែងជាអត្ថបទសំរាប់អានបន្ថែម នៅក្នុងមុខវិជ្ជាផ្សេងៗ ។

សរុបសេចក្តីមក អង្គប្រជុំបានឯកភាព សម្រេចដាក់ឯកសារនេះ ***ជាឯកសារពិគ្រោះ សំរាប់ជាមូលដ្ឋានក្នុងការតាក់តែង និពន្ធមេរៀនប្រវត្តិវិទ្យា ឱ្យសិស្សសិក្សានៅសាលារៀនចំណេះទូទៅ*** ។

អង្គប្រជុំបានបញ្ចប់នាវេលាម៉ោងប្រាំកន្លះ ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសយោគយល់ និងរីករាយ ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦

លេខាកត់ត្រា

[illegible]

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ

អ៊ឹម សិទ្ធិ